- បំផុស និងអំពាវនាវគ្រប់មជ្ឈដ្ឋាន និងសប្បុរសជនដើម្បីជួយឧបត្ថម្ភគាំទ្រ "និទានប្រធម៌ជាតិ"

មាត្រា ៥ ._ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

មាត្រា ៦ ._ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជួយសម្របសម្រួលថវិកាជូនគណៈកម្មការនេះតាមតម្រូវការជាក់ស្តែង ។

មាត្រា ៧ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និង វិចិត្រសិល្បៈ គណៈកម្មការរៀបចំបុណ្យជាតិ អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ២៥ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មការរៀបចំនិទានហោរាស្រ្តអន្តរ ឆ្នាំ ១៩៩៩-២០០០

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- យោងតាមការចាំបាច់នៃកាលានុវត្តភាពបើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាច់សតវត្សទី២០

## សំរេច

មាត្រា ១ ._ បង្កើតគណៈកម្មការរៀបចំទិវាហោរាស្រ្តអន្តរឆ្នាំ ១៩៩៩-២០០០ មួយ ដែលមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២- ឯកឧត្តម មិន ឃិន រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង ជាអនុប្រធាន
៣- ឯកឧត្តម ម៉ែន យ៉េត រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន
៤- ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការក្រសួងទេសចរណ៍ ជាអនុប្រធាន
៥- ឯកឧត្តម គង់ ទិមុល រដ្ឋលេខាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
៦- ឯកឧត្តម អ៊ុច គឹមអន រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
៧- ឯកឧត្តម អ៊ី តារាទុធ រដ្ឋលេខាធិការក្រសួងពត៌មាន ជាសមាជិក
៨- ឯកឧត្តម ថ្លៃ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាសមាជិក
៩- ឯកឧត្តម ស៊ឹង គង់ អគ្គនាយករងអាជ្ញាធរអប្សរា ជាសមាជិក
១០- ឯកឧត្តម ប៉ាន់ ចាន់ត្រា ប្រធានអាកាសចរណ៍ស៊ីវិល ជាសមាជិក
១១- ឯកឧត្តម អភិបាលខេត្តសៀមរាប ជាសមាជិក
១២- លោក ស៊ឹម សុផល ប្រធាននាយកដ្ឋានអង្គរក្សក្រសួងមហាផ្ទៃ ជាសមាជិក
១៣- លោក ខៀវ ថវិកា ប្រធាននាយកដ្ឋានពត៌មានទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

មាត្រា ២.- ឆ្លងតាមរយៈទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ គណៈកម្មការនេះមានបេសកកម្មបង្ហាញជូនទស្សនាវម្មណ៍ជាតិ និងអន្តរជាតិនូវ :

- អត្តសញ្ញាណជាតិខ្មែរតំណវង្សពីអង្គរ
- វប្បធម៌ អារ្យធម៌ដ៏រុងរោចន៍នាសម័យអង្គរ ផ្សារភ្ជាប់នឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល នាបច្ចុប្បន្នក្នុងជំហរលើកកំពស់ :

ក-ការពង្រឹងសន្តិភាព
ខ-ផ្សះផ្សារជាតិ និងបង្រួបបង្រួមជាតិ
គ-សាមគ្គីធម៌ជាតិ និងអន្តរជាតិ
ឃ-ការស្តារវិរភាព កិត្តិយស និងសីលធម៌រស់នៅថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្មែរ
ង-តាមរូបភាព និងខ្លឹមសារនៃទស្សនីយភាពប្រែក្លាយទិវាមហោស្រពនេះអោយទៅជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិភពលោកមួយសំដៅបំបាត់រាល់ការបង្អាប់បង្អួចកេរ្តិ៍ឈ្មោះខ្មែរ ពីសំណាក់បរទេសក្នុងរយៈពេលកន្លងមកដោយប្តេជ្ញាទទួលខុសត្រូវវាសនាខ្លួនឯងនៅថ្ងៃអនាគត ។

មាត្រា ៣.- ដើម្បីសំរេចនូវបេសកកម្មខាងលើនេះ គណៈកម្មការរៀបចំទិវាមហោស្រពឆ្នាំ ១៩៩៩-២០០០ មានភារកិច្ចដូចតទៅ :

- បើកអង្គប្រជុំជាញឹកញាប់ដើម្បីពិភាក្សាពិគ្រោះយោបល់ និងបែងចែកភារកិច្ចដែលពាក់ព័ន្ធនឹងជំនាញមុខសញ្ញាជូនសមាជិកទទួលខុសត្រូវរៀងៗខ្លួន
- ធ្វើសារាចរណែនាំស្តីពីការប្រារព្ធទិវាមហោស្រពឆ្នាំ ១៩៩៩-២០០០
- រៀបចំគំរោងប្រធានបទ ខ្លឹមសារ រូបភាពបំរើអោយទិវាមហោស្រពនេះ
- បង្កើតអនុគណៈកម្មការមួយចំនួនដើម្បីប្រគល់ភារកិច្ចដោយឡែកតាមភាពចាំបាច់ ។

- តាមដានត្រួតពិនិត្យ កែសំរួលជាជំហានៗ នូវរាល់សកម្មភាពរបស់ផ្នែកនីមួយៗ
- បំផុស និងអំពាវនាវគ្រប់មជ្ឈដ្ឋានជាតិ និង អន្តរជាតិ ប្រជាជន មហាជន សប្បុរសជន ដើម្បីជួយឧបត្ថម្ភគាំទ្រចំពោះទិវាមហោស្រពនេះ
- បំផុសអោយមហាជន ទេសចរជាតិ និងអន្តរជាតិចូលរួមក្នុងទិវាមហោស្រពនេះអោយបានកុះករ
- ធ្វើវេទយិតកម្មអប់រំដល់មន្ត្រីរាជការ នគរបាល កងទ័ព សិស្ស និស្សិត ប្រជាពលរដ្ឋគ្រប់ស្រទាប់ និងព្រះសង្ឃនៅទូទាំងព្រះរាជាណាចក្រកម្ពុជាអោយជួយជ្រោងខ្ពស់ទិវាមហោស្រពប្រវត្តិសាស្ត្រនេះ
- ផ្សព្វផ្សាយ និងអំពាវនាវចំពោះសិប្បករខ្មែរអោយខិតខំសំរាំងស្នាដៃផលិតនូវវត្ថុសិល្បៈពាក់ព័ន្ធ នឹងវប្បធម៌អារ្យធម៌អង្គរជាពិសេសប្រជាពលរដ្ឋខេត្តសៀមរាបទាំងមូល ដើម្បីលក់យកកំរៃនៅកំឡុងពេលប្រព្រឹត្តទៅនៃមហោស្រពនេះ
- ត្រៀមលក្ខណៈរៀបចំទីលានមុខប្រាសាទអង្គរវត្ត ដើម្បីសំដែង និងប្រារព្ធពិធី
- រកគ្រប់លទ្ធភាពបើកប្រាសាទមួយចំនួនទៀត ដូចជាទីលានជល់ដំរី និងស្រះស្រង់ ជាដើម សំរាប់ធ្វើនិទស្សន៍អំពីឆ្នាំសន្តិភាព ទេសចរណ៍ ចំពោះមជ្ឈដ្ឋានជាតិ និងអន្តរជាតិ

មាត្រា ៤ ._ កំណត់យកថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ ជាថ្ងៃពិធីបើកមហោស្រព ( ថ្ងៃចូលបុណ្យ )

-ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៩ និងថ្ងៃទី ០១ ខែមករា ឆ្នាំ២០០០ ជាទិវាប្រកាសបិទ/បើកសតវត្ស និង ឆ្នាំ សន្តិភាព ទេសចរណ៍ ដោយ សម្តេចនាយករដ្ឋមន្ត្រី

-និងថ្ងៃអាទិត្យទី០២ ខែមករា ឆ្នាំ ២០០០ ជាថ្ងៃបិទមហោស្រព ។

មាត្រា ៥ ._ គណៈកម្មការជាតិរៀបចំទិវាមហោស្រពឆ្នាំ ១៩៩៩-២០០០ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៦ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះចាត់ទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ គណៈកម្មការរៀបចំបុណ្យជាតិ អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន អាជ្ញាធរអប្សារា និងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★